# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ២៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០២៣-២០២៨

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១០៧ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការតែងតាំងនិងផ្តល់ឋានៈ ដល់សមាសភាពថ្នាក់ដឹកនាំ សមាជិក សមាជិកាអចិន្ត្រៃយ៍ មិនអចិន្ត្រៃយ៍ ទីប្រឹក្សាជាន់ខ្ពស់ ទីប្រឹក្សាបច្ចេកទេស នៃក.ស.រ. អគ្គលេខាធិការនិងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក.ស.រ.
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០២៣-២០២៨ ដែលមានសមាសភាព ដូចខាងក្រោម៖

១. ឯកឧត្តម **ថង វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

| | | |
|---|---|---|
| ២. ឯកឧត្តម **ឆែម គារតិទ្ធិ** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣. ឯកឧត្តម **គី តិច** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៤. ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
| ៥. ឯកឧត្តម **អេង ទូច** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦. ឯកឧត្តម **ឈាង វណ្ណារិទ្ធ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៧. ឯកឧត្តម **ស៊ា ម៉ៅ** | រដ្ឋលេខាធិការ | សមាជិក |
| ៨. លោកជំទាវ **ឆាយ វ៉ាន់ឡើន** | រដ្ឋលេខាធិការ | សមាជិកា |
| ៩. ឯកឧត្តម **សុក ផេង** | រដ្ឋលេខាធិការ | សមាជិក |
| ១០. ឯកឧត្តម **ខូយ ឃុនហ៊ួរ** | រដ្ឋលេខាធិការ | សមាជិក |
| ១១. ឯកឧត្តម **ហែម គ្រាញ់តូនី** | រដ្ឋលេខាធិការ | សមាជិក |
| ១២. លោកជំទាវ **ទុង សុគន្ធ** | រដ្ឋលេខាធិការ | សមាជិកា |
| ១៣. ឯកឧត្តម **ឈួន ឆាម** | រដ្ឋលេខាធិការ | សមាជិក |
| ១៤. ឯកឧត្តម **អេង កុកថាយ** | រដ្ឋលេខាធិការ | សមាជិក |
| ១៥. ឯកឧត្តម **ថោង សុជាតិ** | រដ្ឋលេខាធិការ | សមាជិក |
| ១៦. ឯកឧត្តម **ហ៊ុយ វណ្ណះ** | រដ្ឋលេខាធិការ | សមាជិក |
| ១៧. ឯកឧត្តម **សូ សុខ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៨. លោកជំទាវ **អ៊ុង ច័ន្ទសោភា** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ១៩. ឯកឧត្តម **ម៉ក់ វ៉េនីតា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២០. លោកជំទាវ **អ៊ុច និពន្ធ** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ២១. ឯកឧត្តម **អ៊ុត ស៊ីណាត** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២២. ឯកឧត្តម **ហ៊ីវ បញ្ញាឧត្តម** | អនុរដ្ឋលេខាធិការ | សមាជិក។ |

**ប្រការ២.-**

ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីស្ដីការគណៈរដ្ឋមន្ត្រី មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំពិនិត្យ និងផ្ដល់ការតម្រង់ទិសលើការរៀបចំឯកសារទស្សនាទាននៃផែនការយុទ្ធសាស្ត្រទីស្ដីការគណៈរដ្ឋមន្ត្រី តាមរយៈការកំណត់ចក្ខុវិស័យ គោលបំណង គោលដៅអាទិភាព ការបែងចែកមុខងារ ការទទួលខុសត្រូវ និងយុទ្ធសាស្ត្រអភិវឌ្ឍស្ថាប័ន របស់អង្គភាពក្រោមឱវាទ
- ដឹកនាំពិនិត្យ និងសម្រេចលើសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រទីស្ដីការគណៈរដ្ឋមន្ត្រី
- ដឹកនាំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រប្រចាំឆមាស
- ពិនិត្យ និងសម្រេចលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផ្ដល់ការណែនាំតម្រង់ទិស ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅអាទិភាព ដែលបានដាក់ចេញ
- ដឹកនាំសម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍ ស្ថាប័នជាតិនិងអន្តរជាតិ ក្រោមកិច្ចសហប្រតិបត្តិការផ្សេងៗ ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងមូលធនមនុស្ស។

**ប្រការ៣.-**

ក្រុមការងារខាងលើមានក្រុមការងារចំពោះកិច្ច ជាសេនាធិការសម្រាប់ជួយរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនេះ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆែម គាតរិទ្ធី** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសនិងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ប្រធាន |
| ២. ឯកឧត្តម **នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត** | អនុប្រធាន ក.ស.វ. | អនុប្រធាន |
| ៣. ឯកឧត្តម **ទួន ថាវរៈ** | អនុប្រធាន ក.ស.វ. | អនុប្រធាន |
| ៤. ឯកឧត្តម **ឈាង វណ្ណារិទ្ធ** | អនុប្រធាន ក.ស.វ. | អនុប្រធាន |
| ៥. ឯកឧត្តម **ចែម ផល្លា** | អនុប្រធាន ក.ស.វ. | អនុប្រធានប្រចាំការ |
| ៦. ឯកឧត្តម **ហ៊ុយ វណ្ណៈ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៧. ឯកឧត្តម **អ៊ូច ចោងសេង** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ៨. ឯកឧត្តម **ប៊ិច សុខា** | សមាជិកអចិន្ត្រៃយ៍និងជាអគ្គលេខាធិការ ក.ស.វ. | សមាជិក |
| ៩. ឯកឧត្តម **អ៊ុំ សំអាង** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ១០. ឯកឧត្តម **នៅ ចោនន័រ** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ១១. ឯកឧត្តម **ជួន រតនៈ** | សមាជិកអចិន្ត្រៃយ៍និងជាអគ្គលេខាធិការរង ក.ស.វ. | សមាជិក |
| ១២. លោកជំទាវ **សែម សុគា** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិកា |
| ១៣. ឯកឧត្តម **លឹម ពុទ្ធិជាតិ** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ១៤. ឯកឧត្តម **ចន្ថា ម៉េងលី** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ១៥. ឯកឧត្តម **ម៉ម សារិទ្ធ** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ១៦. ឯកឧត្តម **ភយ បូរី** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ១៧. ឯកឧត្តម **អេង រត្នមុនី** | សមាជិកអចិន្ត្រៃយ៍ ក.ស.វ. | សមាជិក |
| ១៨. ឯកឧត្តម **ឈន ថុង** | អគ្គនាយក | សមាជិក |
| ១៩. ឯកឧត្តម **រិទ្ធ អារុណនិត្យា** | អគ្គនាយក | សមាជិក |
| ២០. ឯកឧត្តម **ឆាំង ហ៊ុយ** | អគ្គនាយក | សមាជិក |
| ២១. ឯកឧត្តម **ចោង សុគន្ធ** | អគ្គនាយក | សមាជិក |
| ២២. ឯកឧត្តម **ឡុង សុខា** | អគ្គនាយក | សមាជិក |
| ២៣. ឯកឧត្តម **សេង ម៉ានោឫទ្ធិ** | អគ្គនាយក | សមាជិក |
| ២៤. ឯកឧត្តម **យឹម សុគន្ធី** | អគ្គនាយករង | សមាជិក |
| ២៥. លោកស្រី **ហែម អ៊ុំសិទ្ធិជាណែល** | ប្រធាននាយកដ្ឋាន | សមាជិក។ |

**ប្រការ៤.-**

ក្រុមការងារចំពោះកិច្ចនេះ មានភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យ គោលបំណង គោលដៅអាទិភាព និងការបែងចែកមុខងារនិងការទទួលខុសត្រូវ ដោយមានការសិក្សា និងវិភាគពីស្ថានភាពបច្ចុប្បន្ន រួមទាំងភាពខ្លាំងនិងភាពខ្សោយ និងភាពប្រទាក់ក្រឡារបស់អង្គភាពក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រីនីមួយៗ

- រៀបចំឯកសារទស្សនាទាន ដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពជំនាញ ក្រុមប្រឹក្សា និងថ្នាក់ដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រ ដើម្បីដាក់ជូនក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ ពិនិត្យ តម្រង់ទិស និងសម្រេច
- កំណត់របៀបរបបនៃការអនុវត្តការងារ រំហូរការងារ និងការទទួលខុសត្រូវ ប្រកបដោយភាពអាចទុកចិត្តបាន ការពង្រឹងក្រមសីលធម៌ និងវិជ្ជាជីវៈការងារ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារប្រចាំថ្ងៃ
- រៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រ រួមបញ្ចូលទាំងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងទិសដៅការងារ អាទិភាពទៅមុខ ជាមួយនឹងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អង្គភាពក្រោមឱវាទ សំដៅឈានទៅសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅអាទិភាពដែលបានដាក់ចេញ ដើម្បីដាក់ជូនក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ ពិនិត្យ និងសម្រេច
- កំណត់យន្តការសម្របសម្រួលរួម និងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ
- សម្របសម្រួល និងបូកសរុបរបាយការណ៍ការអនុវត្តផែនការយុទ្ធសាស្ត្រពីអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រប្រចាំត្រីមាស ជូនក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីពិនិត្យ និងផ្ដល់ការណែនាំតម្រង់ទិស
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍ ស្ថាប័នជាតិនិងអន្តរជាតិ ក្រោមកិច្ចសហប្រតិបត្តិការផ្សេងៗ ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងមូលធនមនុស្ស
- អនុវត្តភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ។

**ប្រការ៥.-**

ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២៣-២០២៨ និងក្រុមការងារចំពោះកិច្ចអាចស្នើសុំមន្ត្រីក្រោមឱវាទនៃទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីជួយសម្រួលការងារតាមការចាំបាច់។

**ប្រការ៦.-**

ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២៣-២០២៨ និងក្រុមការងារចំពោះកិច្ចមានសិទ្ធិអញ្ជើញ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ សមាជិក សមាជិកា និងទីប្រឹក្សា ក.ស.វ. ដើម្បីចូលរួមប្រជុំ និងប្រមូលធាតុចូលបន្ថែម តាមការចាំបាច់។

**ប្រការ៧.-**

សមាសភាពដូចមានចែងក្នុងប្រការ ១ និង ៣ ខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេច ដើម្បីចូលរួមជំនួស ក្នុងករណីអវត្តមាន។

**ប្រការ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ